# មហាវិទ្យាល័យវិស្វកម្មអគ្គិសនី (មហាវិទ្យាល័យថាមពលចិន-អាស៊ាន) នៃសាកលវិទ្យាល័យក្វាងស៊ី

# កម្មវិធីអាហារូបករណ៍របស់ក្រុមហ៊ុនChina Southern Power Grid(CSG)ឆ្នាំ 2025

# មគ្គុទ្ទេសក៍ណែនាំស្តីពីការចុះឈ្មោះនិស្សិតអន្តរជាតិ

សូមស្វាគមន៍សិស្សនិស្សិតដាក់ពាក្យចូលរៀននៅមហាវិទ្យាល័យវិស្វកម្មអគ្គិសនី(មហាវិទ្យាល័យថាមពលចិន-អាស៊ាន)នៃសាកលវិទ្យាល័យក្វាងស៊ី !  សាកលវិទ្យាល័យក្វាងស៊ីគឺជាសាកលវិទ្យាល័យក្នុងគម្រោងវិស្វកម្ម 211 និង គម្រោងបង្កើតសកលវិទ្យាល័យ "double first-class" និងជាគ្រឹះស្ថានឧត្តមសិក្សា "សហប្រតិបត្តិការរួមគ្នា" រវាងក្រសួងអប់រំចិន និងរដ្ឋបាលតំបន់ស្វយ័តជនជាតិជាំង។ សាកលវិទ្យាល័យក្វាងស៊ីមានធនធានអប់រំ និងបរិយាកាសសិក្សាដ៏ល្អ។ មហាវិទ្យាល័យវិស្វកម្មអគ្គិសនី(មហាវិទ្យាល័យថាមពលចិន-អាស៊ាន) នៃសាកលវិទ្យាល័យក្វាងស៊ី ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1938 ដែលមានទីតាំងនៅទីក្រុងណាននីងស្ថិតនៅតំបន់ស្វយ័តក្វាងស៊ី។ ទីក្រុងណាននីងមិនត្រឹមតែជា "ទីក្រុងបៃតង " ដ៏ស្រស់ស្អាតប៉ុណ្ណោះទេ ថែមទាំងជាទីក្រុងដំបូងក្នុងកិច្ចសហប្រតិបត្តិការរវាង ប្រទេសចិនជាមួយនឹងតំបន់អាស៊ានផងដែរ។ បច្ចុប្បន្ននេះមហាវិទ្យាល័យមានការជំនាញfirst classគោលថ្នាក់ជាតិកម្រិតបរិញ្ញាបត្រ(វិស្វកម្មអគ្គិសនីនិងស្វ័យប្រវត្តិកម្ម) និងជំនាញវិស្វកម្មអគ្គិសនីកម្រិតអនុបណ្ឌិត និងបណ្ឌិត។ មហាវិទ្យាល័យយើងប្រមូលផ្តុំទៅដោយគ្រូបង្រៀនថ្នាក់ជាតិ ហើយបានបង្កើតជាវេទិកាសិក្សាអប់រំថ្នាក់ជាតិ ថែមទាំងមានការបំពាក់គ្រឿងបរិក្ខារបង្រៀនគ្រប់គ្រាន់ និងហេដ្ឋារចនាសម្ព័ន្ធបែបទំនើប។

អាហារូបករណ៍China Southern Power Grid (CSG) គឺជាអាហារូបករណ៍100% ដែលបង្កើតឡើងដោយក្រុមហ៊ុន China Southern Power Grid Co., Ltd. រួមសហការជាមួយនឹងសាកលវិទ្យាល័យក្វាងស៊ី ដើម្បីបណ្តុះបណ្តាលសិស្សនិស្សិតថ្នាក់បរិញ្ញាបត្រ(និស្សិតអន្តរជាតិ) ជំនាញផ្នែកវិស្វកម្មអគ្គិសនីនិងស្វ័យប្រវត្តិកម្ម និងនិស្សិតថ្នាក់អនុបណ្ឌិតជំនាញវិស្វកម្មអគ្គិសនី (និស្សិតអន្តរជាតិ) ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍន៍អាជីវកម្មរបស់ក្រុមហ៊ុននៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន។

ខាងក្រោមនេះជាសេចក្តីណែនាំអំពីព័ត៌មានលម្អិតនៃអាហារូបករណ៍សម្រាប់ការសិក្សានៅប្រទេសចិន៖

## ១.ប្រភេទនៃសិស្សនិស្សិតចូលរៀននិងអាហារូបករណ៍

| កម្មវិធីសិក្សា | ជំនាញ | ឆ្នាំសិក្សា | ថ្នាក់បំប៉នភាសាចិន | សុពលភាពអាហារូបករណ៍ | ថ្នាក់សិក្សា |
|---|---|---|---|---|---|
| បរិញ្ញាបត្រ | វិស្វកម្មអគ្គិសនីនិងស្វ័យប្រវត្តិកម្ម | 4ឆ្នាំ | 1ឆ្នាំ | 1+4ឆ្នាំ | ពេញម៉ោង |

| | | | | | |
|---|---|---|---|---|---|
| អនុបណ្ឌិត | វិស្វកម្មអគ្គិសនី | 3ឆ្នាំ | - | 0+3ឆ្នាំ | ពេញម៉ោង |

បញ្ជាក់៖

1) ប្រសិនបើបេក្ខជនដាក់ពាក្យមានកម្រិតHSK 4 ឬខ្ពស់ជាងនេះ បេក្ខជនអាចស្នើសុំចូលសិក្សាជំនាញតែម្តងដោយមិនបាច់រៀនត្រៀមភាសាចិនមួយឆ្នាំនោះទេ ដូចនេះសុពលភាពអាហារូបករណ៍ក៏មិនទទួលបានការរៀនបំប៉នភាសាចិនរយៈពេល1ឆ្នាំដូចគ្នា។

2) ភាសានៃការបង្រៀន៖ ក្រៅពីវគ្គបំប៉នភាសាចិនរយៈពេល1ថ្នាក់ ថ្នាក់ជំនាញត្រូវបានបង្រៀនជាភាសាចិន។

## ២. ឆ្នាំសិក្សា និងវគ្គសិក្សា

កម្មវិធីសិក្សាសំរាប់ថ្នាក់បរិញ្ញាបត្រមានរយៈពេល 4ឆ្នាំ និងថ្នាក់អនុបណ្ឌិតមានរយៈពេល 3 ឆ្នាំ។

សាកលវិទ្យាល័យក្វាងស៊ីចែកចេញជាពីរឆមាស៖ ឆមាសទី១ វគ្គសិក្សានិទាឃរដូវ(Spring) និងឆមាសទី២ វគ្គសិក្សារដូវស្លឹកឈើជ្រុះ(Autumn)។ វគ្គសិក្សារដូវស្លឹកឈើជ្រុះគឺជាការបើកបវេសនកាលឆ្នាំសិក្សាថ្មី ជាទូទៅចាប់ពីខែកញ្ញាដល់ខែមករា និងវគ្គសិក្សានិទាឃរដូវចាប់ពីខែកុម្ភៈដល់ខែមិថុនា។

## ៣. លក្ខខណ្ឌសម្រាប់ការស្នើសុំចុះឈ្មោះ

1. មិនមានសញ្ជាតិចិន កាន់លិខិតឆ្លងដែនបរទេសដែលមានសុពលភាព។

2. បេក្ខជនត្រូវមានសញ្ជាតិក្នុងប្រទេសតំបន់អាស៊ាន រឺបុគ្គលិកដែលត្រូវបានចាត់តាំងដោយក្រុមហ៊ុន China Southern Power Grid (CSG)សម្រាប់គម្រោងក្រៅប្រទេស។

3. មានសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្ត និងគ្រប់តាមស្តង់ដារសុខភាពសម្រាប់ការដាក់ពាក្យសុំទិដ្ឋាការសិក្សា ឬប័ណ្ណស្នាក់នៅក្នុងប្រទេសចិន។

4. បេក្ខជនដែលមកបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅប្រទេសចិន ត្រូវតែមានសញ្ញាបត្រដែលមានតម្លៃស្មើនឹងថ្នាក់បរិញ្ញាបត្រនៃសាកលវិទ្យាល័យចិន។

5. បេក្ខជនត្រូវមានភាពរួសរាយរាក់ទាក់ ឧស្សាហ៍ព្យាយាម និងខិតខំរៀនសូត្រ មានសមត្ថភាពសិក្សាល្អ អាកប្បកិរិយាល្អ និងគោរពច្បាប់។ បេក្ខជនមិនមានកំណត់ត្រានៃការបំពានច្បាប់ និងបទប្បញ្ញត្តិនានារបស់សាលា គ្មានការពិន័យសន្តិសុខសាធារណៈ និងគ្មានកំណត់ត្រាព្រហ្មទណ្ឌ។

6. កម្រិតភាសា៖ បេក្ខជនដែលដាក់ពាក្យមកសិក្សានៅប្រទេសចិនថ្នាក់អនុបណ្ឌិតចាំបាច់ត្រូវតែមានភាសាចិនកម្រិត4(HSK4) ដែលមានពិន្ទុចាប់ពី 180ឡើងទៅ។

7. បេក្ខជនស្នើសុំអាហារូបករណ៍សម្រាប់ថ្នាក់បរិញ្ញាបត្រត្រូវមានអាយុក្រោម 30 ឆ្នាំ (កើតក្រោយថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ១៩៩៤) ហើយបេក្ខជនអាហារូបករណ៍សម្រាប់ថ្នាក់អនុបណ្ឌិតត្រូវតែមានអាយុក្រោម ៣៥ ឆ្នាំ (កើតក្រោយថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ១៩៩០)។

## ៤. ការស្នើសុំអាហារូបករណ៍

ការចុះឈ្មោះចូលរៀនរបស់និស្សិតអន្តរជាតិឆ្នាំសិក្សា2025 គឺកំពុងបើកដំណើរការ។ ឆមាសថ្មីនឹងចាប់ផ្តើមនៅថ្ងៃទី 26 ខែសីហា ឆ្នាំ 2025។ ប្រសិនបើសិស្សនិស្សិតមានចំណាប់អារម្មណ៍មកសិក្សានៅមហាវិទ្យាល័យវិស្វកម្មអគ្គិសនីនៃសាកលវិទ្យាល័យក្វាងស៊ី សូមអានការណែនាំនៃការដាក់ពាក្យដូចខាងក្រោម

(១) ចូលទៅក្នុងប្រព័ន្ធដើម្បីចុះឈ្មោះ

បេក្ខជនដែលដាក់ពាក្យតាមអ៊ីនធឺណិត(Online Application) សូមចុចលីងខាងក្រោមដើម្បីដាក់ពាក្យតាមអនឡាញ៖

http://gxu.at0086.cn/StuApplication/Login.aspx

ឬស្កេន QR កូដខាងក្រោមដើម្បីចុះឈ្មោះ៖




(២) ការជ្រើសរើស"招生项目"

ការស្នើសុំតាមប្រព័ន្ធអ៊ីនធឺណិត បេក្ខជនគ្រាន់តែបង្កើតគណនីផ្ទាល់ខ្លួនជាមួយនឹងអាសយដ្ឋានអ៊ីមែលរបស់លោកអ្នកជាការស្រេច បន្ទាប់មកលោកអ្នកអាចចាប់ផ្តើមដាក់ពាក្យស្នើសុំបានភ្លាមៗ។ ពេលបំពេញទិន្នន័យ ក្នុងប្រអប់ "招生项目"សូមជ្រើសយកពាក្យ "中国南方电网公司奖学金"។

(៣)ឯកសារពាក់ព័ន្ធមានដូចខាងក្រោម៖

បញ្ជាក់: ① ប្រសិនបើបេក្ខជនដាក់ពាក្យស្នើសុំថ្នាក់បរិញ្ញាបត្រ សូមផ្តល់ឯកសារដូចខាងក្រោម ឯកសារលេខ 1, 2, 3, 4, 5, 6 និង9។

② ប្រសិនបើបេក្ខជនដាក់ពាក្យស្នើសុំថ្នាក់អនុបណ្ឌិត សូមផ្តល់ឯកសារខាងក្រោម ឯកសារលេខ 1, 2, 3, 4, 5, 6, 7, 8, និង9។

1. រូបថត (ថតពាក់កណ្តាលខ្លួនជាមួយនឹងផ្ទៃខាងក្រោយពណ៌ស)
2. ប័ណ្ណសុខភាព (អាចទាញយកបានពីតំណខាងក្រោម https://gjxy.gxu.edu.cn/gjxy_en/info/1035/1151.htm)
3. ថតចម្លងលិខិតឆ្លងដែន (ទំព័ររូបថត និងទំព័រទិដ្ឋាការ)
4. វិញ្ញាបនបត្រ HSK (កម្រិត ៤ ឬខ្ពស់ជាងនេះ)
5. វិញ្ញាបនបត្រកម្រិតសិក្សាខ្ពស់បំផុត (ឯកសារត្រូវបកប្រែជាភាសាចិន ឬអង់គ្លេស)

6. ព្រឹត្តិបត្រពិន្ទុកម្រិតសិក្សាខ្ពស់បំផុត (ឯកសារត្រូវបកប្រែជាភាសាចិន ឬអង់គ្លេស)

7. លិខិតណែនាំ(Recommendation)ចំនួនពីរច្បាប់ជាភាសាអង់គ្លេស ឬភាសាចិនដែល សរសេរដោយសាស្ត្រាចារ្យរង ឬលើសពីនេះ (និស្សិតថ្នាក់អនុបណ្ឌិត តម្រូវឱ្យផ្តល់ឯកសារនេះ)

8. ផែនការសិក្សា (និស្សិតថ្នាក់អនុបណ្ឌិត តម្រូវឱ្យផ្តល់ឯកសារនេះ)

9. លិខិតថ្កោលទោស

(៤)ដាក់ពាក្យស្នើសុំ

បន្ទាប់ពីបំពេញទម្រង់បែបបទពាក្យស្នើសុំ និងបញ្ចូលឯកសារដែលពាក់ព័ន្ធរួច បេក្ខជនត្រូវចុចពាក្យស្នើសុំក្នុងប្រព័ន្ធចុះឈ្មោះ។

## ៥. អំពីដំណើរការជ្រើសរើស

បញ្ជីឈ្មោះជាប់អាហារូបករណ៍នឹងត្រូវប្រកាសចន្លោះពី 4ទៅ8សប្តាហ៍ បន្ទាប់ពីការបិទការស្នើសុំដាក់ពាក្យ។ ក្នុងអំឡុងពេលនេះ យើងខ្ញុំនឹងជូនដំណឹងដល់បេក្ខជនឱ្យបំពេញរាល់ឯកសារពាក់ព័ន្ធបន្ថែម ហើយសហការជាមួយក្រុមហ៊ុន Guangxi Power Grid ដើម្បីពិនិត្យនិងវាយតម្លៃឯកសារ និងរៀបចំធ្វើការសម្ភាសន៍ក្នុងលក្ខខណ្ឌចាំបាច់។ ប្រសិនបើបេក្ខជន ត្រូវបានជ្រើសរើស យើងខ្ញុំនឹងផ្ញើជូននូវឯកសារចូលរៀន និងឯកសារពាក់ព័ន្ធនានា។ យើងខ្ញុំនឹងព្យាយាមផ្ញើព័ត៌មាននៃការចូលរៀនឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## ៦. ដំណើរការស្នើសុំទិដ្ឋាការ

សូមយកលិខិតចុះឈ្មោះចូលរៀន និងពាក្យស្នើសុំទិដ្ឋាការដែលចេញដោយសាកលវិទ្យាល័យរបស់យើងខ្ញុំទៅស្ថានទូតចិនដែលស្ថិតនៅក្នុងប្រទេសរបស់អ្នក ដើម្បីដាក់ពាក្យស្នើសុំទិដ្ឋាការសិក្សា។ បន្ទាប់ពីបានមកដល់សាកលវិទ្យាល័យក្វាងស៊ីសូមដាក់ពាក្យស្នើសុំប័ណ្ណស្នាក់នៅ។ សិស្សនិស្សិតតម្រូវឱ្យមានប័ណ្ណស្នាក់នៅក្នុងប្រទេសចិន ទើបមានសិទ្ធិសិក្សា និងរស់នៅក្នុងប្រទេសចិនដោយស្របច្បាប់។

បញ្ជាក់៖ ប័ណ្ណស្នាក់នៅគឺជាឯកសារសំខាន់សម្រាប់ការស្នាក់នៅរបស់លោកអ្នកនៅក្នុងប្រទេសចិន។ បន្ទាប់ពីសាកលវិទ្យាល័យក្វាងស៊ីទទួលលោកអ្នកមកសិក្សា និងបង់ថ្លៃសិក្សារួច យើងខ្ញុំនឹងជួយលោកអ្នកក្នុងការស្នើសុំលិខិតអនុញ្ញាតស្នាក់នៅ។

## ៧. ថ្ងៃផុតកំណត់នៃការដាក់ពាក្យ

ដើម្បីធានាសកម្មភាពបង្រៀនត្រូវបានអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ សូមបំពេញការចុះឈ្មោះមុន ម៉ោង 24:00 ថ្ងៃទី 30 ខែមិថុនា ម៉ោងនៅទីក្រុងប៉េកាំង។

## ៨. ព័ត៌មានទាក់ទងនឹងអាហារូបករណ៍

ប្រាក់ឧបត្ថម្ភសម្រាប់និស្សិតអន្តរជាតិនីមួយៗរួមមានថ្លៃសិក្សា កន្លែងស្នាក់នៅ ប្រាក់ចំណាយប្រចាំថ្ងៃ ថ្លៃធានារ៉ាប់រងជាដើម។ ប្រាក់ចំណាយប្រចាំថ្ងៃរួមមានប្រាក់ឧបត្ថម្ភ ផ្នែកខ្លះនៃថ្លៃព្យាបាល ថ្លៃពិនិត្យសុខភាព ថ្លៃទិដ្ឋាការ/ប័ណ្ណស្នាក់នៅ ថ្លៃស្នាក់នៅ ថ្លៃធ្វើដំណើរ ថ្លៃចុះឈ្មោះប្រលង HSK-4/HSK-5 ថ្លៃសម្ភារៈសិក្សា។ល។

## ៩.កន្លែងស្នាក់នៅ

និស្សិតថ្នាក់បរិញ្ញាបត្រ និងនិស្សិតថ្នាក់អនុបណ្ឌិតទាំងអស់នៃសាកលវិទ្យាល័យក្វាងស៊ីត្រូវបានស្នាក់នៅអគារនិស្សិតអន្តរជាតិរបស់សាកលវិទ្យាល័យដោយក្នុងមួយបន្ទប់សម្រាប់មនុស្ស 4 នាក់ ។

## ១០. ទាក់ទងមកយើងខ្ញុំ


លោកគ្រូChen ការិយាល័យមជ្ឈមណ្ឌលសេវាកម្មនិស្សិតអន្តរជាតិនៃសាកលវិទ្យាល័យក្វាងស៊ី

អ៊ីមែល៖ lxs@gxu.edu.cn

ទូរស័ព្ទ៖ +86-771-3235229

WeChat៖ STUDY-AT-GXU

គេហទំព័រ៖ www.gxu.edu.cn

gjxy.gxu.edu.cn

លោកគ្រូ Zhou មហាវិទ្យាល័យវិស្វកម្មអគ្គិសនីនៃសាកលវិទ្យាល័យក្វាងស៊ី

លោកគ្រូ He មហាវិទ្យាល័យវិស្វកម្មអគ្គិសនីនៃសាកលវិទ្យាល័យក្វាងស៊ី

អ៊ីមែល៖ dqxylxs@gxu.edu.cn

ទូរស័ព្ទ៖ +86-771-3224191

WeChat៖ (-)

គេហទំព័រ៖ www.gxu.edu.cn

លោកគ្រូ Wang មជ្ឈមណ្ឌលអភិវឌ្ឍន៍ទេពកោសល្យនៃក្រុមហ៊ុនបណ្តាញថាមពលក្វាងស៊ី

អ៊ីមែល៖ 3088138213@qq.com

ទូរស័ព្ទ៖ +86-771-5693857

WeChat: sugarbutter123